**សេចក្តីប្រកាសព័ត៌មាន**

**ទាក់ទង៖ នៅភ្នំពេញ លោក ប៊ូ សារឿន** (855) 12-217-301
sbou@worldbank.org
**នៅវ៉ាស៊ីនតោន៖ លោកស្រី អេលីហ្សាប៊េត មែលី** (202) 458 4475
emealey@worldbank.org

# ធនាគារពិភពលោកពិភាក្សាលើកំណែទម្រង់

**ភ្នំពេញ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៩** - អនុប្រធានធនាគារពិភពលោកសម្រាប់តំបន់អាស៊ីបូព៌ា និងបាស៊ីហ្វិក លោក ជីម អាដាម បានមកទស្សនាកិច្ចកម្ពុជារយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី ២៧ ដល់ ២៨ ខែ សីហា ឆ្នាំ ២០០៩ ដើម្បីជួបពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ តំណាងអង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជន ។

ដំណើរទស្សនកិច្ចនេះ គឺជាផ្នែកមួយនៃដំណើរទស្សនកិច្ចក្នុងតំបន់ដែលចាប់ផ្តើមពីប្រទេសកម្ពុជា ប្រទេស ទីម័រលេស្តេ និងប្រទេសចិន ។ លោក អាដាមមកទស្សនកិច្ចកម្ពុជាដើម្បីពិភាក្សា និងពិនិត្យមើលកម្មវិធីដែលធនាគារពិភពលោកគាំទ្រនៅប្រទេសកម្ពុជា ជាពិសេសលើវិស័យកំណែទម្រង់ដីធ្លី វិមជ្ឈការនិងវិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍវិស័យឯកជន ។

លោក អាដាម បានពិភាក្សាជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលអំពីផលប៉ះពាល់ដែលបណ្តាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោកមកលើតំបន់ជាទូទៅ និងមកលើកម្ពុជាដោយឡែក និងលើវិធីសាស្ត្រនានាសំរាប់កាត់បន្ថយផលប៉ះពាល់នៃវិបត្តិនេះ ជាពិសេសចំពោះប្រជាជនកម្ពុជាដែលងាយទទួលរងគ្រោះ ។

ការផ្តោតអារម្មណ៍ជាសំខាន់ចំពោះដំណើរទស្សនកិច្ចនេះ គឺវិស័យដីធ្លីនៅតំបន់ទីក្រុងរបស់កម្ពុជា និងការកើនឡើងជម្លោះ និងការបណ្តេញចេញប្រជាជនក្រីក្រដែលរស់នៅទីក្រុង ។ ដំណើរទស្សនកិច្ចនេះក៏បានពិភាក្សាលើរបាយការណ៍ស្តីពីការពិនិត្យលើការធ្វើឱ្យប្រសើរឡើងវិញនៃគម្រោងគ្រប់គ្រងដីធ្លី និងរដ្ឋបាល ដែលរបាយការណ៍នេះ រៀបចំឡើងដើម្បីឆ្លើយតបទៅនឹងសំណួរដែលលើកឡើងថា គម្រោងនេះអាចជាប់ទាក់ទិននឹងជម្លោះទាំងនោះ ។

ការពិភាក្សាអំពីកំណែទម្រង់ដីធ្លីមានលក្ខណៈស្ថាបនា និងបានព្រមព្រៀងគ្នាដើម្បីពិភាក្សាបន្តទៀតនៅសប្តាហ៍ក្រោយៗ សម្រាប់កំណត់ជំហានដែលត្រូវធ្វើបន្ទាប់ ។